គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

គ.ជ.ប

# ព្រឹត្តិបត្រ

លេខ ០២

## គោលនយោបាយគណបក្ស

### សម្រាប់ការឃោសនាបោះឆ្នោត

### ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤

ថ្ងៃបោះឆ្នោត៖ នៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧


អាសយដ្ឋាន៖ ទីស្តីការ គ.ជ.ប លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

Phone/Fax: (+855)23 214 374 | E-mail: necinfo@forum.org.kh

Website: www.necelect.org.kh, www.voterlist.org.kh

Facebook: www.facebook.com/CambodiaNEC

# មាតិកា


| ឈ្មោះគណបក្សនយោបាយ | ទំព័រ |
|---|---|
| ❖ គណបក្ស ប្រជាធិបតេយ្យមូលដ្ឋាន | ១ |
| ❖ គណបក្ស យុវជនកម្ពុជា | ២ |
| ❖ គណបក្ស ហ្វ៊ុន ស៊ិន ប៉ិច | ៣ |
| ❖ គណបក្ស អំណាចខ្មែរ | ៤ |
| ❖ គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ | ៥ |
| ❖ គណបក្ស សង្គ្រោះជាតិ | ៦ |
| ❖ គណបក្ស ប្រជាជនកម្ពុជា | ៧ |
| ❖ គណបក្ស សាធារណរដ្ឋប្រជាធិបតេយ្យ | ៨ |
| ❖ គណបក្ស សញ្ជាតិកម្ពុជា | ៩ |
| ❖ គណបក្ស សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ១០ |
| ❖ គណបក្ស ខ្មែររួបរួមជាតិ | ១១ |
| ❖ គណបក្ស ជនជាតិដើមប្រជាធិបតេយ្យកម្ពុជា | ១២ |

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ
នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

**ផ្ញើជូនជនរួមជាតិ បងប្អូន កូនក្មួយ ជាទីគោរពស្នេហាដ៏ជ្រាលជ្រៅបំផុត**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ នឹងប្រព្រឹត្តទៅនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ ខាងមុខនេះ ។ ក្នុងឱកាសនេះ ខ្ញុំសូមអំពាវនាវជាឱឡារិក ជូនជនរួមជាតិ បងប្អូន កូនក្មួយ អ្នកបោះឆ្នោតទាំងអស់ សូមមេត្តាអញ្ជើញទៅបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ។

ការបោះឆ្នោតនៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ គឺជាការបោះឆ្នោតជាទូទៅជាសកល ដោយសម្ងាត់ តាមលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្ស ដូចនេះសុំកុំឱ្យមានការព្រួយបារម្ភពីការគាបសង្កត់ ការគម្រាមកំហែង ឬសម្ពុតពីជនណាម្នាក់ ឬបក្សណាមួយឱ្យសោះ ។

ខ្ញុំសូមបងប្អូន កូនក្មួយ មេត្តាប្រើសិទ្ធិសេរីភាពរបស់ខ្លួន បោះឆ្នោតទៅតាមសតិសម្បជញ្ញៈរបស់ខ្លួនម្នាក់ៗ ដែលមានទំនុកចិត្តទៅលើបេក្ខជនណាម្នាក់ គណបក្សនយោបាយណាមួយ ។

សូមបងប្អូន កូនក្មួយ ជនរួមជាតិទាំងអស់ ប្រកបនូវព្រះពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងមេត្តាទទួលនូវសេចក្តីគោរពស្នេហាដ៏ជ្រាលជ្រៅជាទីបំផុត អំពីខ្ញុំ ។

នសីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ៤០ ខែកុម្ភៈ ឆ្នាំ២០១៧

គោលនយោបាយអភិវឌ្ឍមូលដ្ឋានសង្ខេបរបស់គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)

# គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)



បណ្ឌិត កែម ឡី ជាបិតាស្ថាបនិកគណបក្សប្រជាធិបតេយ្យមូលដ្ឋាន



លោក យ៉េង វិរៈ ប្រធានគណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)



លោក សាម ស៊ុនឿន អនុប្រធានគណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)



បណ្ឌិត យ៉ង់ សាំងកុមារ ប្រធានកម្មវិធីពង្រឹងសមត្ថភាពថ្នាក់ដឹកនាំមូលដ្ឋាន គបម



បណ្ឌិត សាម ស៊ីន អគ្គលេខាធិការគណបក្សប្រជាធិបតេយ្យមូលដ្ឋាន

ដើម្បីដឹកនាំអភិវឌ្ឍឃុំភូមិឲ្យរីកចម្រើន **គណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម)** បានរៀបចំគោលនយោបាយអភិវឌ្ឍមូលដ្ឋានចំនួន១៦ចំណុច ហើយបានសង្ខេបខ្លីមកត្រឹមប្រាំចំណុច។ បើសិនប្រជាពលរដ្ឋបោះឆ្នោតឲ្យគណបក្សប្រជាធិបតេយ្យមូលដ្ឋាន (គបម) គឺអ្នកភូមិយើងទទួលបានមេឃុំមេភូមិល្អ គ្រូពេទ្យល្អ គ្រូបង្រៀនល្អ គ្រូកសិកម្មល្អ និងនគរបាល (ប៉ូលីស) ល្អ។

**១-មេឃុំមេភូមិល្អ៖** អ្នកភូមិយើងឈប់រើសអើងបែកបាក់គ្នាដោយសារនិន្នាការនយោបាយ, អ្នកភូមិយើងចេះសហការគ្នាអភិវឌ្ឍភូមិឃុំ, អ្នកភូមិយើងទទួលបានសេវារដ្ឋបាលសាធារណៈល្អ, អ្នកភូមិយើងជ្រើសរើសមេភូមិដោយផ្ទាល់តាមរយៈការបោះឆ្នោត, អ្នកភូមិយើងមានផ្លូវល្អ ទឹកស្អាត និងភ្លើងអគ្គិសនីប្រើប្រាស់ និងអ្នកភូមិយើងទទួលបានការសម្របសម្រួលដោះស្រាយទំនាស់ប្រកបដោយយុត្តិធម៌។

**២-គ្រូពេទ្យល្អ គ្រូបង្រៀនល្អ គ្រូកសិកម្មល្អ៖** អ្នកភូមិយើងទទួលបានសេវាថែទាំសុខភាព និងព្យាបាលល្អ, កូនចៅអ្នកភូមិយើងចាប់ពីអាយុ៣ឆ្នាំឡើងទៅទទួលបានសេវាអប់រំល្អ និងកសិករយើងទទួលបានទឹក ទុន ទីផ្សារ និងបច្ចេកទេសកសិកម្ម។

**៣-នគរបាល (ប៉ូលីស) ល្អ៖** អ្នកភូមិយើងទទួលបានសន្តិសុខ និងសុវត្ថិភាព, ភូមិឃុំគ្មានគ្រឿងញៀន និងភូមិឃុំគ្មានបងតូចបងធំ និងក្មេងទំនើង។

➡ បន្ថែមពីលើនេះ **គបម** មានគោលការណ៍ឲ្យសមាជិកបក្សតាមមូលដ្ឋានបោះឆ្នោតដកសេចក្តីទុកចិត្តពីមេឃុំ ក្នុងករណីមេឃុំ គបម ប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។

**គបម** ជម្រុញលើកទឹកចិត្តឲ្យមនុស្សល្អៗមានសមត្ថភាពនៅតាមមូលដ្ឋានមានឱកាសក្លាយជាមេឃុំ ចៅសង្កាត់ដើម្បីបម្រើប្រជាពលរដ្ឋឲ្យបានល្អ។

**គបម** បានបង្កើតគោលការណ៍ប្រជាធិបតេយ្យផ្ទៃក្នុងបក្សពីក្រោមមកលើដោយអនុញ្ញាតឲ្យសមាជិកបក្សតាមមូលដ្ឋានបោះឆ្នោតជ្រើសរើសលេខរៀងបេក្ខជនក្រុមប្រឹក្សាឃុំ សង្កាត់ដោយផ្ទាល់។

**គបម** មានក្រុមការងារថ្នាក់ជាតិដើម្បីជួយពង្រឹងឃុំ សង្កាត់ដែលដឹកនាំដោយ គបម ឲ្យក្លាយជាឃុំ សង្កាត់គំរូក្នុងការបម្រើប្រជាពលរដ្ឋ៕

គបម មានគោលនយោបាយអភិវឌ្ឍមូលដ្ឋានសង្ខេបសំខាន់ល្អ៥ចំណុច, បោះឆ្នោតឲ្យ គបម បានល្អ៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**គណបក្សយុវជនកម្ពុជា**
Cambodian Youth Party
*យុវជនដើម្បីការអភិវឌ្ឍន៍*

# គោលនយោបាយ
# ឃុំ-សង្កាត់របស់គណបក្សយុវជនកម្ពុជា
# សម្រាប់ក្នុងអាណត្តិទី៤ ឆ្នាំ២០១៧

គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មាធិការនាយក និងគណៈកម្មាធិការប្រតិបត្តិរាជធានីខេត្តរបស់គណបក្សយុវជនកម្ពុជាបានសម្រេចដាក់ចេញគោលនយោបាយ ឃុំ-សង្កាត់ ក្នុងការចូលរួមប្រកួតប្រជែងនយោបាយក្នុងអាណត្តិបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៤ ឆ្នាំ២០១៧ ខាងមុខមាន៥ចំណុចដូចខាងក្រោមនេះ៖

1. បង្កើតមុខរបរជូនពលរដ្ឋក្នុងតំបន់ និងនៅទីកន្លែង ដើម្បីសង្គ្រោះសេដ្ឋកិច្ចពលរដ្ឋខ្មែរ
2. បង្កើតទីផ្សារកសិកម្មក្នុងមូលដ្ឋានឃុំ ហើយគ្រប់គ្រងតម្លៃទីផ្សារដោយមន្ត្រីថ្នាក់ឃុំ គឺមិនមែនគ្រប់គ្រងតម្លៃទីផ្សារដោយឈ្មួញឡើយ ដើម្បីលើកកម្ពស់ជីវភាពកសិករខ្មែរ
3. លុបបំបាត់ការយកសេវាសាធារណៈគ្រប់ប្រភេទពីពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានឃុំ
4. បង្កើតសាលារៀនបច្ចេកទេសក្នុងមូលដ្ឋានឃុំ ដើម្បីផ្តល់ឱកាសដល់យុវជនក្រីក្របានសិក្សាដោយមិនយកថ្លៃការសិក្សាឡើយ
5. លុបបំបាត់ការចរាចរគ្រឿងញៀនគ្រប់ប្រភេទ ដើម្បីលើកកម្ពស់ស្មារតីយុវជន ព្រមទាំងបញ្ចប់អំពើហិង្សា និងចោរកម្មនៅក្នុងមូលដ្ឋានឃុំ

ក្រោយពីគណបក្សយុវជនកម្ពុជាឈ្នះឆ្នោតដឹកនាំ ឃុំ-សង្កាត់ គណបក្សយុវជនកម្ពុជានឹងធានាឲ្យបានជាដាច់ខាតក្នុងការអនុវត្តនូវគោលនយោបាយខាងលើ ដើម្បីសង្គ្រោះម្ចាស់ឆ្នោតឲ្យរួចផុតពីទុក្ខលំបាកក្នុងជីវភាពប្រចាំថ្ងៃ។

អាសយដ្ឋាន_ផ្ទះលេខ៨៨១ ផ្លូវ៧៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ ទំនាក់ទំនង 071 5 76 77 78



### ៤. សុខមាលភាព និងសង្គមកិច្ច

- ខិតខំរៀបចំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត និងរៀបចំកម្មវិធីចុះពិនិត្យជម្ងឺជូនដល់ប្រជាពលរដ្ឋនៅតាមបណ្តាលមូលដ្ឋានឃុំ/សង្កាត់ និមណ្ឌលសុខភាពនានា។
- រៀបចំឲ្យមានរថយន្ត ឬមធ្យោបាយសមស្របអាចដឹកជញ្ជូន អ្នកជម្ងឺសង្គ្រោះបន្ទាន់ទៅមណ្ឌលសុខភាព ឬមន្ទីរពេទ្យ ។
- ជម្រុញគ្រូពេទ្យអោយយកចិត្តទុកដាក់ពិនិត្យ និងព្យាបាលជម្ងឺជូនប្រជាពលរដ្ឋនៅក្នុងមណ្ឌលសុខភាព ជាពិសេស ចាស់ជរា មាតាទារក និងអ្នកទទួលសង្គ្រោះបន្ទាន់ដោយគ្មានការរើសអើង ។
- មិនឲ្យអ្នកជម្ងឺស្លាប់ដោយខ្វះប្រាក់សម្រាប់ព្យាបាលឡើយ ។

### ៥. សិក្សាអប់រំ យុវជន និងកីឡា

- លើកកម្ពស់អភិវឌ្ឍធនធានមនុស្សសម្រាប់ការសិក្សាអប់រំទាំងក្នុង និងក្រៅប្រព័ន្ធ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ។
- ផ្តល់ការលើកទឹកចិត្តដល់លោកគ្រូ អ្នកគ្រូ អោយយកចិត្តទុកដាក់បង្ហាត់បង្រៀនសិស្ស ស្របតាមក្រមសីលធម៌ និងវិជ្ជាជីវៈ ។
- បង្កលក្ខណៈងាយស្រួលក្នុងការសិក្សា និងកីឡាជូនដល់យុវជនយុវនារី គង់មលដាន ដើម្បីកាយសម្បទារឹងមាំ និងប្រាជាកីឡា ។



### ៦. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- ពង្រឹងកម្លាំងនគរបាលប៉ុស្តិ៍រដ្ឋបាល ឲ្យគោរពច្បាប់ និងក្រមសីលធម៌ យកចិត្តទុកដាក់ខ្ពស់ក្នុងកិច្ចការពារសន្តិសុខជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ។
- ផ្តល់ជូននូវសុខសុវត្ថិភាពល្អនៅក្នុងមូលដ្ឋាន (មិនឲ្យមានចោរលួចចោរប្លន់ជួញដូរ សេពគ្រឿងញៀន ល្បែងស៊ីសង បទល្មើសនេសាទក្រុមបងតូចបងធំនៅក្នុងមូលដ្ឋានឡើយ)។
- នគរបាលរដ្ឋបាល ធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនប្រជាពលរដ្ឋតាមលំនៅដ្ឋានដោយមិនយកកម្រៃ។



### ៧. ដីធ្លី

- ទប់ស្កាត់ការរឹបអូស រំលោភយកដីធ្លី ផ្ទះសម្បែងរបស់ប្រជាពលរដ្ឋដោយខុសច្បាប់ពីសំណាក់អ្នកមានអំណាច និងអ្នកមានលុយ ។
- រៀបចំស្នើផ្តល់ដីសង្គមកិច្ច និងការធ្វើប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលគ្មានដីធ្វើកសិកម្ម និងលំនៅដ្ឋានតាមការជាក់ស្តែង ។

### ៨. បរិស្ថាន និងធនធានធម្មជាតិ

- រៀបចំគម្រោងចងក្រងសហគមន៍ការពារព្រៃឈើនៅមូលដ្ឋាន ដើម្បីទប់ស្កាត់ និងលុបបំបាត់ភាពអនាធិបតេយ្យកាប់បំផ្លាញព្រៃឈើ ។
- បង្កើតការគ្រប់គ្រង និងត្រួតពិនិត្យឲ្យមានប្រសិទ្ធភាព ចំពោះការបង្ហូរកាកសំណល់នៃសិប្បកម្មរោងចក្រទាំងឡាយណាដែលអាចបង្កឲ្យខូចបរិស្ថាន និងប៉ះពាល់សុខភាពប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ/សង្កាត់ ។

**ចប់**

៣- មេឃុំ និងចៅសង្កាត់ របស់ គណបក្សអំណាចខ្មែរ ដែលជាប់ឆ្នោត នឹងប្រើអំណាចជា រដ្ឋាភិបាលមូលដ្ឋាន ហៅពលរដ្ឋ និងកសិករ ដែលមានដីស្រែ ដីចម្ការ និងដីលំនៅដ្ឋានដែលមិនទាន់មានប្លង់ទន់ឲ្យមកធ្វើប្លង់ទន់ទាំងអស់កាន់កាប់ដីឲ្យស្របច្បាប់ ដោយឥតគិតថ្លៃ !
រយៈកាលកន្លងមក ពលរដ្ឋដែលមានស្រែ ដីចម្ការ និងដីភូមិ ហើយមិនទាន់មានលិខិតកាន់កាប់ដីធ្លីជាប្លង់រឹងស្របច្បាប់នោះ ក៏ព្រោះតែ មេឃុំ ចៅសង្កាត់ ចាស់ៗទាំងអស់នោះ មិនព្រមធ្វើលិខិតបញ្ជាក់ការកាន់កាប់ដីធ្លី និងមិនបានផ្តល់ប្លង់ទន់ឲ្យពលរដ្ឋទេ ។ ដូច្នោះមេឃុំចៅសង្កាត់នៃគណបក្សអំណាចខ្មែរ ដែលជាប់ឆ្នោត នឹងរៀបចំជួយធ្វើប្លង់ទន់ជូនកសិករ ជាពលរដ្ឋខ្មែរ ទាំងអស់ឲ្យមានលិខិតកាន់កាប់ដីធ្លី ជាប្លង់ទន់ ដោយឥតប្រកាន់និន្នាការនយោបាយគណបក្សឡើយ ។

៤- មេឃុំ និង ចៅសង្កាត់ របស់ គណបក្សអំណាចខ្មែរ នឹងសហការណ៍ជាមួយ កសិករខ្មែរក្នុងឃុំសង្កាត់ បង្កើតសភាកសិករ ឃុំ-សង្កាត់ ដើម្បីការពារតំលៃផលកសិកម្ម និងទាមទារឲ្យផលកសិកម្មរបស់កសិករលក់បានថ្លៃ ពិសេសស្រូវ ដំឡូង ពោត សណ្តែក និងបន្លែ ផ្លែឈើ របស់កសិករខ្មែរ !
រយៈកាលកន្លងមក កសិករ ដាំដំឡូង ពោត សណ្តែក ល្ពៅ បន្លែ ឬធ្វើស្រូវបាន គឺត្រូវបានពួកឈ្មួញ អ្នកមានអំណាច មានលុយ វាយទម្លាក់ថ្លៃកសិផល របស់កសិករ ។ ដូច្នោះ ដើម្បីលើកតំលៃផលិតផលរបស់កសិករខ្មែរឲ្យមានតំលៃ និងធានាតំលៃរបស់ កសិករនៅក្នុងឃុំ សង្កាត់ នោះ មេឃុំ ឬចៅសង្កាត់ នៃគណបក្សអំណាចខ្មែរ ដែលជាប់ឆ្នោត យើងនឹងរៀបចំឲ្យមាន ក្រុមសភាកសិករថ្នាក់ឃុំ សង្កាត់ ដើម្បីជួយការពារកសិករខ្មែរឲ្យមានយុត្តិធម៌ក្នុងការលក់ដូរផលិតផលកសិកម្ម ស្របតាមតំលៃទីផ្សារ ។

៥- មេឃុំ និងចៅសង្កាត់ របស់ គណបក្សអំណាចខ្មែរ នឹងធ្វើឲ្យ នគបាលរដ្ឋបាល ឃុំ សង្កាត់ ក្លាយជាអ្នកការពារ និងបម្រើពលរដ្ឋពិតប្រាកដនិងធ្វើឲ្យមេភូមិគ្រប់ភូមិក្លាយជាជំនួយការ និងជាលេខារបស់ពលរដ្ឋពិតប្រាកដ លែងជាមេធ្មប់ មេអាព របស់ ធានាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ មកសម្លុតគំរាមបំភ័យ កសិករ តទៅទៀត !

កន្លងមក ប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលតាម ឃុំ សង្កាត់ មួយចំនួនធំ មិនបានដើរតួរនាទីជា អ្នកការពារពលរដ្ឋ និងជាអ្នកជួយសម្របសម្រួលកិច្ចការរដ្ឋបាលជូនពលរដ្ឋទេ តែបែជាយកតួនាទី និងប្រាក់ខែ ដែលរដ្ឋាភិបាលផ្តល់ឲ្យ ទៅបម្រើនិងការពារផលប្រយោជន៍ គណបក្សកាន់អំណាច ហើយបង្កើតឲ្យមានការរើសអើងនយោបាយ ជាមួយនឹង គណបក្សនយោបាយផ្សេង នៅថ្នាក់ក្រោម ។ ដូច្នោះ មេឃុំ ចៅសង្កាត់ គណបក្សអំណាចខ្មែរ នឹងធ្វើការកែទម្រង់រដ្ឋបាលថ្នាក់ឃុំ សង្កាត់ ធ្វើឲ្យនគរបាល រដ្ឋបាលឃុំ សង្កាត់ ឯករាជ្យ លែងបម្រើគណបក្ស ។នេះ ជាកម្មវិធីនយោបាយមូលដ្ឋាន និងការពន្យល់ !

សូមប្អូនយកអាន បញ្ចូលភ្លេង សម្រាប់យកឲ្យប៉ុស្តិ៍វិទ្យុ !   សិករខ្មែរ ៖



ម៉ម សូណង់ដូ

# គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ

## គោលការណ៍សំខាន់ ដើម្បីផ្តល់ជីវភាព និង ភាពថ្លៃថ្នូរ ដល់ប្រជាពលរដ្ឋ ក្នុងឃុំ និងសង្កាត់

## ឃុំ ជាបេះដូង របស់ប្រជាពលរដ្ឋ

១. បោសសំអាត អំពើពុករលួយ គ្រឿងញៀន ល្បែងស៊ីសង និងបំរើសេវាសាធារណៈ ដោយគោរពតាមច្បាប់កំណត់ ។

២. ប្រជាពលរដ្ឋត្រូវមានបាយទទួលទាន មានពេទ្យព្យាបាល មានការសិក្សា ប្រកបដោយគុណភាព និងក្រមសីលធម៌ ។

៣. ការពារដីធ្លី លំនៅដ្ឋាន និងទប់ស្កាត់បទល្មើសនេសាទខុសច្បាប់ ។

៤. ជួសជុល និងកសាងបន្ថែមហេដ្ឋារចនាសម្ព័ន្ធ ដូចជា៖ លូបង្ហូរទឹក ផ្លូវលំ ស្ពាន ទំនប់ទឹក ប្រឡាយទឹក ស្រះទឹក អណ្តូងទឹក ។

៥. បង្កើតក្លិបកីឡាសំរាប់យុវជន បង្កើតការងារ និងតំបន់ទេសចរណ៍ រក្សាសន្តិសុខ បរិស្ថាន អនាម័យ ។

**គណបក្ស សំបុកឃ្មុំសង្គមប្រជាធិបតេយ្យ**

ស្មោះត្រង់ ឧស្សាហ៍ ឆ្លៀតប្រាជ្ញា ប្ដូរជីវិតដើម្បីជាតិ

# គណបក្សសង្គ្រោះជាតិ

## CAMBODIA NATIONAL RESCUE PARTY

**សង្គ្រោះ បម្រើ ការពារ**

### គោលនយោបាយអាទិភាព ៥ចំណុច

*គណបក្សសង្គ្រោះជាតិ* (**គ.ស.ជ**) ដាក់ចេញនូវគោលនយោបាយរបស់ខ្លួនលើគ្រប់វិស័យ សម្រាប់ការអភិវឌ្ឍន៍ឃុំ-សង្កាត់ឲ្យក្លាយទៅជាឃុំ-សង្កាត់សកម្ម ដែលមានសកម្មភាពរស់រវើកក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ។

គោលនយោបាយអាទិភាពទាំង ៥ចំណុច ដែលក្នុងនោះ ៤ចំណុច ជាគោលនយោបាយចម្បង ដែលមេឃុំ-ចៅសង្កាត់មកពី **គ.ស.ជ** ត្រូវធ្វើមុនគេ បន្ទាប់ពីឈ្នះការបោះឆ្នោតឃុំ-សង្កាត់ នាថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៧។ ចំណែកគោលនយោបាយអាទិភាពទី៥ ជាគោលនយោបាយថ្នាក់ជាតិរបស់ **គ.ស.ជ** ក្នុងការធ្វើវិមជ្ឈការថវិកា ដើម្បីអភិវឌ្ឍន៍ឃុំ-សង្កាត់ នៅពេល **គ.ស.ជ** ឈ្នះឆ្នោតឆ្នាំ២០១៨ ដឹកនាំរាជរដ្ឋាភិបាល។

**គោលនយោបាយអាទិភាព ៥ចំណុច នោះរួមមាន៖**

**១. ពង្រឹងសិទ្ធិអំណាចប្រជាពលរដ្ឋ៖**

- ផ្តល់ឱកាស និងលើកទឹកចិត្តប្រជាពលរដ្ឋ បង្កើតសហគមន៍ ចូលរួមផ្តល់យោបល់ និងវាយតម្លៃ ក្នុងការធ្វើសេចក្តីសម្រេចនានាក្នុងឃុំ-សង្កាត់។

**២. លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ និងអភិវឌ្ឍន៍**

- ការពារកម្មសិទ្ធិដីធ្លីស្របច្បាប់របស់ប្រជាពលរដ្ឋ និងមិនចុះហត្ថលេខាលើការវិនិយោគ ឬសម្បទានដែលប៉ះពាល់ដល់ផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋ។
- ប្រឹក្សាយោបល់ និងផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋពាក់ព័ន្ធនឹងការខ្ចីបុល និងទីផ្សារកសិផល។
- អភិវឌ្ឍន៍ និងវិនិយោគដោយផ្តល់ផលប្រយោជន៍ ជាអាទិភាពដល់ប្រជាពលរដ្ឋក្នុងឃុំ-សង្កាត់។

**៣. សេវាសាធារណៈ**

- ផ្តល់លិខិតស្នាមផ្សេងៗ ដោយមិនរើសអើង ស្អាតស្អំ និងទាន់ពេលកំណត់។
- បង្កើតមូលនិធិសម្រាប់ជួយជនងាយរងគ្រោះ។

**៤. សន្តិសុខ**

- ពង្រឹងប្រសិទ្ធភាព និងលើកកម្ពស់ការងារនគរបាល ដើម្បីឃុំ-សង្កាត់ប្រកបដោយសុវត្ថិភាព គ្មានគ្រឿងញៀន និងគ្មានអំពើហិង្សា។

**៥. វិមជ្ឈការ** (គោលនយោបាយថ្នាក់ជាតិសម្រាប់ឃុំ-សង្កាត់)

- វិមជ្ឈការអំណាច៖ ប្រគល់សិទ្ធិអំណាច ធ្វើសេចក្តីសម្រេចចិត្តក្នុងការអភិវឌ្ឍឃុំ-សង្កាត់។
- វិមជ្ឈការថវិកា៖ ផ្តល់ថវិកាយ៉ាងតិច ៥០០.០០០$ (ហាសិបម៉ឺនដុល្លារអាមេរិក) សម្រាប់ឃុំ-សង្កាត់នីមួយៗ ក្នុងមួយឆ្នាំ ស្មើនឹងប្រមាណ២០% នៃថវិកាជាតិ។
- វិមជ្ឈការសេវាសាធារណៈក្នុងវិស័យអាទិភាព៖ (អប់រំ សង្គមកិច្ច ប្រព័ន្ធទឹកស្អាត ផ្លូវឃុំ-សង្កាត់ និងផ្តល់អ្នកជំនាញបច្ចេកទេសកសិកម្ម សុខាភិបាល)។

**គោលបំណងរបស់ គ.ស.ជ គឺធ្វើឱ្យ ៖** ឃុំ-សង្កាត់ មានការចូលរួមពីប្រជាពលរដ្ឋ ក្នុងការពិគ្រោះ និងផ្តល់យោបល់សម្រាប់ការសម្រេចសំខាន់ៗ។ ឃុំ-សង្កាត់មានសេវាសាធារណៈប្រកបដោយគុណភាព ស្អាតស្អំ រហ័សទាន់ពេល។ ឃុំ-សង្កាត់មានសុវត្ថិភាព រស់នៅដោយសុខដុមរមនា សុភមង្គល គ្មានអំពើហិង្សា គ្មានគ្រឿងញៀន គ្មានការរើសអើង។ល។ យើងរួបរួមគ្នាធ្វើឱ្យឃុំ-សង្កាត់យើងមានភាពល្អប្រសើរឡើងថែមទៀត ដោយធ្វើឱ្យការបង្កើត កសាងសហគមន៍កាន់តែខ្លាំងក្លាឡើងថែមទៀត ដែលធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ-សង្កាត់ រឹងរឹតតែធូរធារប្រសើរឡើងថែមទៀត៕

***សន្លឹកឆ្នោតខ្ញុំ ដើម្បីឃុំ-សង្កាត់ខ្ញុំ!***

**គណបក្សសង្គ្រោះជាតិ**

**គ.ស.ជ**

ឯករាជ្យ សន្តិភាព សេរីភាព ប្រជាធិបតេយ្យ

អព្យាក្រឹត និង វឌ្ឍនភាពសង្គម

# គោលនយោបាយសំខាន់ៗសម្រាប់អាណត្តិ ឃុំ សង្កាត់ ឆ្នាំ ២០១៧-២០២២ របស់គណបក្សប្រជាជនកម្ពុជា

១- ឃុំ សង្កាត់ទទួលបានធនធានហិរញ្ញវត្ថុមិនតិចជាង ២,៨% នៃចំណូលចរន្តថវិកាជាតិប្រចាំឆ្នាំ ហើយអត្រានេះនឹងត្រូវបង្កើនបន្ថែមទៀតដើម្បីលើកកម្ពស់ការអភិវឌ្ឍឃុំ សង្កាត់

២- ប្រជាកសិករទទួលបានការគាំទ្រពីរដ្ឋដើម្បីធានាការបង្កើនផលិតកម្ម និងការរកទីផ្សារសម្រាប់លក់កសិផលដោយមានតម្លៃសមរម្យ

៣- ខិតខំកាត់បន្ថយអត្រាការប្រាក់ក្នុងវិស័យមីក្រូហិរញ្ញវត្ថុឲ្យស្ថិតក្នុងកម្រិតសមរម្យ និងពង្រឹងកិច្ចការពារ ប្រជាជនក្រីក្រដែលជាអ្នកខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុ

៤- ប្រជាជនគ្មានដី ឬ ខ្វះដី នឹងទទួលបានដីសម្រាប់សង់លំនៅឋាន និងបង្កបង្កើនផល តាមរយៈការអនុវត្តកម្មវិធីសម្បទានដីសង្គមកិច្ច

៥- ផ្តល់ជូនប្រជាជនដោយឥតគិតថ្លៃនូវសេវាចុះបញ្ជីកំណើត ចុះបញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព សៀវភៅគ្រួសារ សៀវភៅស្នាក់នៅ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

៦- ប្រជាជនគ្រប់រូបទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺកាន់តែល្អប្រសើរតាមមណ្ឌលសុខភាព និងមន្ទីរពេទ្យរបស់រដ្ឋ។ ប្រជាជនក្រីក្រ និងអ្នកខ្វះលទ្ធភាពទទួលបានសេវាពិនិត្យ និងព្យាបាលជំងឺដោយឥតបង់ ថ្លៃនៅតាមមណ្ឌលសុខភាព និងតាមមន្ទីរពេទ្យរបស់រដ្ឋ

៧- ឃុំ សង្កាត់នីមួយៗមានអនុវិទ្យាល័យមួយយ៉ាងតិច ក្រុង ស្រុក ខណ្ឌនីមួយៗមានវិទ្យាល័យមួយយ៉ាងតិច និងមានសាលាបឋមសិក្សាច្រើនពង្រាយតាមភូមិ ដើម្បីឲ្យកុមារ និងយុវជនបានរៀនសូត្រគ្រប់គ្នា

៨- អភិវឌ្ឍប្រព័ន្ធទឹកស្រោចស្រពជំណាំ និងទឹកស្អាតសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅ នៅគ្រប់ឃុំ សង្កាត់

៩- តបណ្តាញអគ្គិសនីដល់គ្រប់ភូមិ និងមានតម្លៃថោក គឺ៦១០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង សម្រាប់អ្នកប្រើមិន លើសពី៥០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ និង៤៨០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោងសម្រាប់អ្នកប្រើមិនលើសពី១០គីឡូវ៉ាត់ម៉ោងក្នុងមួយខែ និងសហគមន៍កសិករប្រើប្រាស់ពេលយប់សម្រាប់បូមទឹកបង្កបង្កើនផល

១០- តភ្ជាប់ផ្លូវគមនាគមន៍ពីទីប្រជុំជនទៅគ្រប់ភូមិ ព្រមទាំងកែលម្អផ្លូវលំជនបទពីផ្លូវដីទៅជាផ្លូវកៅស៊ូ ឬផ្លូវបេតុង

១១- កសាងឃុំ សង្កាត់នៅជាប់ព្រំដែនជាមួយប្រទេសជិតខាង ជាឃុំ សង្កាត់ប្រកបដោយសន្តិភាព និងការអភិវឌ្ឍ ប្រជាជនរស់នៅទាំងសងខាងព្រំដែនមានចំណងមិត្តភាព និងសហប្រតិបត្តិការល្អ

១២- អាជីវករលក់ដូរតាមផ្សារដែលស្ថិតលើទីតាំងដីរបស់រដ្ឋ អាចផ្ទេរសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលទៅកូនចៅ ឬអ្នកដទៃបាន ដោយមិនមានកំណត់អាណត្តិ

១៣- ឃុំ សង្កាត់ មានសុវត្ថិភាពកាន់តែល្អប្រសើរ តាមរយៈការអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពឲ្យ កាន់តែមានប្រសិទ្ធភាព ដោយដាក់ចេញនូវវិធានការថ្មីៗបន្ថែមទៀត ព្រមទាំងលើកទឹកចិត្តដល់អង្គភាព អ្នកពាក់ព័ន្ធដែលមានស្នាដៃល្អ និងអនុវត្តវិធានការវិន័យចំពោះសមត្ថកិច្ចដែលអសកម្ម ឬខុសឆ្គង ។

### បញ្ឈប់ពលកម្មកុមារបម្រើតាមផ្ទះ

ប្រទេសកម្ពុជាទើបបានឆ្លងផុតពីសង្គ្រាមដែលកើតឡើងផ្ទួនៗគ្នា ធ្វើអោយប្រជាជនកម្ពុជាភាគច្រើនមានជីវភាពក្រីក្រ ខ្វះចំណេះ និងមានកំណើនកុមារ និងបានចេញទាំងធ្វើការតាមផ្ទះ គ្រប់រូបភាព រួមទាំងទម្រង់ធ្ងន់ធ្ងរក៏កើនឡើងជាលំដាប់ ។ ដោយយល់ពីមូលហេតុផ្សេងៗដែលនាំអោយឈានដល់ស្ថានភាពអាក្រក់បែបបនេះ និងដើម្បីទប់ស្កាត់ឈានដល់ការលុបបំបាត់រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យបានបង្កើតយន្តការពិសេសៗ និងផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិ មានទាំងអនុសញ្ញាស្តីពីសិទ្ធកុមារ ពិធីសាបន្ថែម ស្តីពីការចូលរួមរបស់កុមារ ។ ជាពិសេស អនុសញ្ញាលេខ ១៨២ ស្តីពីការហាមប្រាម និងការលុបបំបាត់ពលកម្មកុមារនៅតាមផ្ទះ ។

### អំពីបន្ទាត់នយោបាយ

១-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ អនុវត្តន៍លទ្ធិប្រជាធិបតេយ្យ សេរីពិតប្រាកដ ។

២-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ ប្រឆាំងអំពើភេរវកម្មគ្រប់ប្រទេស ។

៣-គណបក្សសាធារណរដ្ឋ គោរពសិទ្ធិមនុស្សសមស្របតាមសេចក្តីប្រកាសជាសកលរបស់អង្គការសហប្រជាជាតិ ។

៤-គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ សហការណ៍លើគ្រប់វិស័យ ចំពោះបុព្វហេតុជាតិ និងអន្តរជាតិដើម្បីរក្សាសន្តិភាពពិភពលោក ។ការឯកភាពជាតិ ការស្តាបនាជាតិ បំរើ ទាមទារការពារអធិបតេយ្យភាពជាតិ និងបុរណភាពទឹកដី ។

### គោលនយោបាយអន្តោប្រវេសន៍នៅកម្ពុជា

ពេលដែលគណបក្សសធារណរដ្ឋប្រជាធិបតេយ្យជាប់ឆ្នោតដឹកនាំរាជរដ្ឋាភិបាល និងជម្រុញអោយក្រុមប្រឹក្សាអ្នកច្បាប់បង្កើតច្បាប់អន្តោប្រវេសន៍អោយបានឆាប់រហ័សបំផុត ដែលប្រទេសនានានៅលើពិភពលោកមានច្បាប់នេះ ។ ដោយអាក័ព្វតែព្រះរាជាណាចក្រកម្ពុជា ចាប់តាំងក្រោយពីការបោះឆ្នោតសកលឆ្នាំ ១៩៩៣ រហូតមកដល់នឹងពេលនេះ ៤អណត្តិរាងមកហើយមានរដ្ឋាភិបាល ជាពិសេសក្រុមប្រឹក្សាអ្នកច្បាប់នៅទីស្តីការគណរដ្ឋមន្ត្រីពុំបានតាក់តែងច្បាប់អន្តោប្រវេសន៍ឡើយ ។ ប្រការដែលពុំបានបង្កើតច្បាប់អន្តោប្រវេសន៍ ដើម្បីគ្រប់គ្រងជនបរទេសបានមករស់នៅលើទឹកដីកម្ពុជា ហើយគឺជាចេតនារបស់រាជរដ្ឋាភិបាលពុំបានបញ្ចេញធន្ទះក្នុងការគ្រប់គ្រងជនបរទេសដែលហូរចូលមកប្រទេសកម្ពុជាយ៉ាងច្រើនសន្ធឹកសន្ធាប់នោះឡើយ ។

### វិធានការ និងវិធីសាស្ត្រ ការគោរពច្បាប់

១- ការគោរពច្បាប់ និងការដោះស្រាយបាតុភាពអវិជ្ជមានក្នុងឃុំ/សង្កាត់:

ពេលជាបើឆ្នោតក្រុមប្រេ៊ីក្សាឃុំ/សង្កាត់ គ.ស.រ.ប មានយុទ្ធសាស្រ្ត ២សំខាន់ៗ ក្នុងការពង្រឹងការគោរពច្បាប់

១/ បង្រៀនបំពាក់បំប៉នច្បាប់: ប្រជារាស្ត្រគ្រប់រូប គ្រប់ជាន់ថ្នាក់ ត្រូវតែចេះច្បាប់ និងធ្វើតាមច្បាប់អោយបានត្រឹមត្រូវ និងជាប់លាប់ ។

២/ ធ្វើអោយច្បាប់មានតំលៃ និងប្រសិទ្ធិភាពខ្ពស់នៃច្បាប់ មិនអនុញ្ញាត្តិអោយបុគ្គលណាម្នាក់បំពានច្បាប់ ហើយប្រព្រឹត្តខុសច្បាប់របស់ប្រទេសជាតិឡើយ ត្រូវតែដាក់ទោសដល់ជនណាដែលធ្វើខុសច្បាប់ មិនគិតពីបក្សពួក មិនគិតពីអំណាច ឬស៊ីសំណូកឡើយ ត្រូវតែអនុវត្តន៍ទៅតាមច្បាប់អ្នកដែលប្រព្រឹត្តខុសច្បាប់ ត្រូវតែទទួលទោសជាធរមាន ។

ដំណោះស្រាយបាតុភាពអវិជ្ជមានក្នុងឃុំ/សង្កាត់មាន ២គឺ៖

១/ បាតុភាពអវិជ្ជមានកើតឡើងដោយសាមនុស្ស គឺ គ.ស.រ.ប យកយុទ្ធសាស្រ្ត ពង្រឹងការគោរពច្បាប់មកកំរិត និងដោះស្រាយបញ្ហានេះ ។

២/ បាតុភាពអវិជ្ជមានកើតឡើងពីធម្មជាតិ គ.ស.រ.ប និងបង្កើតផែនការទុកជាមុន ដើម្បីទប់ស្កាត់គ្រោះធម្មជាតិផ្សេងៗស្វែងរកមូលនិធិបន្ថែមលើមូលនិធិដែលមានស្រាប់ទុកដោះស្រាយនៅពេលដែលមានបញ្ហានេះកើតឡើង ។

**បោះឆ្នោតជូន**

# គណបក្ស សញ្ជាតិកម្ពុជា

## សញ្ជាតិ សាសនា អធិបតេយ្យ

ដើម្បីទទួលបានសេចក្តីសុខទាំងផ្លូវកាយ ផ្លូវចិត្តនិងផ្លូវសង្គមព្រមទាំងទទួលបាននូវការអភិវឌ្ឍប្រកបដោយចិរភាពទាំងពេលបច្ចុប្បន្ននិងទៅអនាគត គណបក្សសញ្ជាតិកម្ពុជាដែលមានសញ្ញាព្រះអាទិត្យនិងព្រះចន្ទជួបគ្នា ត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍៖

គ.ស.ក

១. សាមគ្គីធម៌

២. ធ្វើបុណ្យ

៣. រក្សាសីល

៤. បណ្តុះនូវគ្រាប់ពូជព្រះនិព្វាន។

| | | |
|---|---|---|
| គ.ស.ក | **គណបក្ស សញ្ជាតិកម្ពុជា** | ✓ |

# គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

១. **គោលដៅ** ៖ សុបិនរួមរបស់ពួកយើង "មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ ដែលនឹងត្រូវធ្វើឲ្យស្តែងឡើងតាមរយៈការប្រែក្លាយយន្តការប្រាំបីចំណុចឲ្យទៅជាច្បាប់។

២. **ចំណុចចាប់ផ្តើម** ៖ បង្កើតមូលដ្ឋានសម្រាប់ការពិចារណា និងការចូលរួមរបស់ប្រជាពលរដ្ឋដោយ ៖

- ពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពី (១)សង្គមប្រជាធិបតេយ្យ (២)របៀបបង្កើតសង្គមប្រជាធិបតេយ្យ និង (៣)ផលសង្គមប្រជាធិបតេយ្យ
- ពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹង (១)អំពីសិទ្ធិរបស់គាត់ក្នុងនាមជាម្ចាស់ប្រទេស (២)ករណីយកិច្ចក្នុងភាពជាម្ចាស់ក្នុងការចូលរួមកសាងប្រទេស និង (៣)អំណាចដែលខ្លួនត្រូវមានដើម្បីអនុវត្តសិទ្ធិ
- ពន្យល់ប្រជាពលរដ្ឋឲ្យយល់ដឹងអំពី (១)គោលដៅ (២)ចំណុចចាប់ផ្តើម (៣)ឥរិយាបថ និង (៤) ធនធានមនុស្សនៃការធ្វើនយោបាយរបស់ គ.ស.ប ដើម្បីបង្កើតសង្គមប្រជាធិបតេយ្យ
- ពន្យល់ប្រជាពលរដ្ឋឲ្យចូលរួមជាមួយ គ.ស.ប ដើម្បីបញ្ចប់ការធ្វើនយោបាយ (១)ដោយការដើរតាម (២)ដោយការស្រលាញ់ និង (៣)ដោយការដឹងគុណ មកជាការធ្វើនយោបាយដោយការរួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ
- ពន្យល់ប្រជាពលរដ្ឋឲ្យចូលរួមជាមួយ គ.ស.ប ដើម្បីបញ្ចប់ការចាត់ទុកព្រះធម៌ជាជំនឿសាសនាមកជាការប្រតិបត្តិព្រះធម៌ដោយការពិចារណារកហេតុផលដើម្បីធ្វើឲ្យជីវិតរស់នៅមានបុព្វហេតុច្បាស់លាស់នៅក្នុងបច្ចុប្បន្នជាតិ
- ពន្យល់ប្រជាពលរដ្ឋឲ្យមានមូលដ្ឋានគ្រឹះសម្រាប់ការអប់រំសីលធម៌ផ្ទាល់ខ្លួន និងការពង្រឹងចំណេះដឹងទូទៅដែលជាមូលដ្ឋាននៃការបញ្ចប់សង្គមដែលពោរពេញទៅដោយការបែងចែកវណ្ណៈទៅជាសង្គមដែលប្រជាពលរដ្ឋរស់នៅដោយស្មើភាពគ្នា
- ពន្យល់ប្រជាពលរដ្ឋដោយប្រើប្រាស់មេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធអំពីជីវិតដើម្បីផ្លាស់ប្តូរផ្នត់គំនិតពីការ អសកម្ម និងអសីលធម៌ឲ្យទៅជាប្រជាពលរដ្ឋមានសីលធម៌ និងសកម្មក្នុងសកម្មភាពសង្គម

៣. **ឥរិយាបថនយោបាយ** ៖ សុចរិតភាពជាបាតគ្រឹះដែលជាអត្តចរិតផង និងជាឧត្តមគតិផងដែលជាខ្លឹមពិប្រាកដរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ ស្របតាមទិសស្លោក "*ដាក់ខ្លួនឲ្យទាប ឬកពាឲ្យសុភា តែការងារឲ្យណាស់*" និងប្រកាន់ខ្ជាប់នូវគំនិតដើម "*យើងបង្កើតបក្សនេះឡើងដើម្បីជាតិ មិនយកប្រយោជន៍ជាតិដើម្បីបក្សឡើយ*" ។

៤. **ធនធានមនុស្ស** ៖ ត្រូវមានគុណសម្បត្តិរបស់បេះដូង (ជួយសង្គ្រោះ មិនអាត្មានិយម ស្អប់អំពើអាក្រក់ និងជាអ្នកបង្ក្រាបអំពើអាក្រក់) និងគុណសម្បត្តិរបស់ខួរក្បាល (មានសមត្ថភាពពិចារណា មានទស្សនវិស័យ មានសកម្មភាពដើម្បីបម្រើទស្សនៈរបស់ខ្លួនឲ្យក្លាយជាការពិតបាន) ជាលក្ខណសម្បត្តិមិនអាចខ្វះបានសម្រាប់ចលនាស្នូលរបស់គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ

# គណបក្សខ្មែររួបរួមជាតិ
# ខ.រ.ជ

## សារលិខិតរបស់លោក ញឹក ប៊ុនឆៃ
## ប្រធានគណបក្សខ្មែររួបរួមជាតិ ថ្លែងជូនចំពោះបងប្អូនជនរួមជាតិខ្មែរ
## នាឱកាសយុទ្ធនាការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤

ខ្ញុំព្រះករុណាខ្ញុំ **ញឹក ប៊ុនឆៃ** ប្រធានគណបក្សខ្មែររួបរួមជាតិ មានកិត្តិយស សូមក្រាបបង្គំសម្តេចព្រះសង្ឃរាជ ទាំង២គណៈ ព្រះករុណាព្រះថេរានុថេរៈ ព្រះសង្ឃគ្រប់ព្រះអង្គជាទីគោរពសក្ការៈ និងសូមធ្វើគារវកិច្ច ជម្រាបសួរលោកតា លោកយាយ មាមីង បងប្អូនជនរួមជាតិជាទីស្នេហានិងគោរពដ៏ខ្ពង់ខ្ពស់។

ថ្ងៃទី ៤ ខែមិថុនា ឆ្នាំ២០១៧ គឺជាថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ ដែលជាឱកាសសំខាន់នៃបងប្អូនជនរួមជាតិ ក្នុងការប្រើប្រាស់សិទ្ធិ អំណាចជ្រើសរើសតំណាងស្របច្បាប់របស់ខ្លួនឲ្យទៅធ្វើការក្នុងឃុំ សង្កាត់សម្រាប់រយៈពេល៥ឆ្នាំ។ គណបក្សខ្មែររួបរួមជាតិ ជាគណបក្សបង្កើតដោយស្ថាបនិកដែលជាអតីតអ្នកស្មោះត្រង់ចំពោះជាតិ សាសនា ព្រះមហាក្សត្រនិងធ្លាប់បានដង្ហែសម្តេចឪក្នុងបុព្វហេតុជាតិ បានសម្រឹតសម្រាំងជ្រើសរើសជាក់បេក្ខភាពដែលមានគុណសម្បត្តិ សមត្ថភាព សច្ចៈ ស្មោះត្រង់ សុចរិតទៀងត្រង់ ដើម្បីឲ្យធ្វើការបម្រើបងប្អូន។

គណបក្សខ្មែររួបរួមជាតិ សូមធានាជាឱឡារិកថា ក្រុមប្រឹក្សាដែលបងប្អូនជ្រើសរើសឲ្យធ្វើការជំនួសនៅក្នុងឃុំ សង្កាត់ខ្លួននោះ នឹងអនុវត្តខ្ជាប់ខ្ជួនតាមគោលការណ៍គណបក្សក្នុងការកសាងនូវ សុខដុមមនេរីយ សន្តិសុខសុវត្ថិភាព វឌ្ឍនភាព ប្រកាន់យុត្តិធម៌ ស្អាតស្អំ សច្ចៈ ទៀងត្រង់ ដើម្បីផលប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់បងប្អូនក្នុងមូលដ្ឋាន ហើយនឹងចាត់វិធានការហ្មឺងម៉ាត់ ដោយតម្លាភាពលើតំណាងណាដែលខកខានមិនអនុវត្តតាមគោលការណ៍គណបក្ស។

គណបក្សខ្មែររួបរួមជាតិ ដែលសមាជិកទាំងអស់គ្នាជាម្ចាស់ផ្ទាល់ តម្កល់ផលប្រយោជន៍ប្រទេសជាតិ ប្រជាពលរដ្ឋដ៏ខ្ពង់ខ្ពស់ និងមានការដឹកនាំគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ គ្មានការរើសអើង បក្ខពួក គ្រួសារនិយម និងពុករលួយ បានកំណត់គោលនយោបាយមូលដ្ឋានអាទិភាពសម្រាប់ដោះស្រាយនៅក្នុងឃុំសង្កាត់ មានចំណុច៩ចំណុច។

គោលនយោបាយមូលដ្ឋានអាទិភាព ៩ចំណុច (<u>**សូមអានគោលនយោបាយអាទិភាពទាំង៩ចំណុច**</u>) នឹងទទួលបានលទ្ធផលល្អប្រសើរនៅពេលដែលបងប្អូនជនរួមជាតិបោះឆ្នោតជ្រើសរើសឲ្យបេក្ខភាពពីគណបក្សខ្មែររួបរួមជាតិ បានទៅធ្វើការក្នុងឃុំ សង្កាត់របស់បងប្អូន ដែលធ្វើការសម្រេចអ្វីមួយត្រូវពិគ្រោះយោបល់និងស្ទបមតិពី ប្រជាពលរដ្ឋម្ចាស់ឆ្នោត។ ដោយពេលវេលាមានកំណត់ គោលនយោបាយមូលដ្ឋានអាទិភាព៩ចំណុច នឹងជម្រាបជូនពិស្តារមួយចំណុចម្តងៗ ដោយវាគ្មិនតំណាងគណបក្សនៅក្នុងវេទិកានានា ដែលនឹងចាក់ផ្សាយតាមកម្មវិធីដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងតាមបណ្តាញផ្សព្វផ្សាយរបស់សង្គមស៊ីវិល។

ខ្ញុំ ព្រះករុណាខ្ញុំ សូមអំពាវនាវដល់បងប្អូនជនរួមជាតិដែលមានសិទ្ធិបោះឆ្នោត មេត្តាអញ្ជើញទៅបោះឆ្នោតឲ្យបានគ្រប់ៗគ្នានៅថ្ងៃទី៤ ខែមិថុនា ឆ្នាំ២០១៧ និងជ្រើសរើសគណបក្សខ្មែររួបរួមជាតិ ដែលមានរូបសញ្ញាមកុដ ជានិមិត្តសញ្ញាតំណាងការរួបរួមគ្នានៃខ្មែរគ្រប់មជ្ឈដ្ឋាន ដើម្បីសាមគ្គី និងឯកភាពជាតិ ការពារ លើកតម្កើងផលប្រយោជន៍ជាតិ និងប្រជាពលរដ្ឋខ្មែរ គោរពរដ្ឋធម្មនុញ្ញ និងស្មោះត្រង់ចំពោះព្រះរាជបល្ល័ង្ក ជាម្លប់ត្រជាក់ផ្តល់នូវសុខក្សេមក្សាន្ត សន្តិភាព និងវឌ្ឍនភាពរុងរឿងនៃកម្ពុជាយើង។

សូមកុំឲ្យឱកាសដ៏មានតម្លៃនេះកន្លងផុតទៅ ដោយការខកខានមិនទៅចូលរួមបោះឆ្នោត ពីព្រោះការបោះឆ្នោតនេះជាការសម្រេចចិត្តរបស់បងប្អូន ដែលកំណត់ ជោគវាសនារបស់បងប្អូនក្នុងមូលដ្ឋានឃុំ សង្កាត់ផ្ទាល់ សម្រាប់រយៈពេល ៥ ឆ្នាំ ពោលគឺបើជ្រើសរើសខុស គឺបាត់បង់និងខាតពេលវេលា ៥ឆ្នាំ។

ខ្ញុំ ព្រះករុណាខ្ញុំ សូមប្រគេន និងប្រសិទ្ធិពរ ថ្វាយ និងជូនចំពោះព្រះថេរានុថេរៈ និងបងប្អូន ជនរួមជាតិ សូមបានគតប្រសព្វនឹងពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងសុភមង្គលគ្រប់ប្រការ។

សូមអរព្រះគុណ និងសូមអរគុណ



**ប្រជាពលរដ្ឋកម្ពុជាជាទីគោរពរាប់អាន និងជាទីស្នេហា!**

ជាបឋម ខ្ញុំសូមសម្តែងនូវការគោរព និងសេចក្តីស្រលាញ់ដ៏ជ្រាវជ្រៅបំផុតចំពោះប្រជាពលរដ្ឋកម្ពុជាទាំងអស់

បន្ទាប់ពីសង្រ្គាមមក ឃើញថាប្រជាពលរដ្ឋ និងជនជាតិដើមភាគតិចមានការរស់នៅប្រកបដោយសេចក្តីសុខទាំងផ្លូវកាយ និងផ្លូវចិត្តព្រោះនៅមានធនធានធម្មជាតិនិងវប្បធម៌របស់ខ្លួនបើទោះជាមិនទាន់មានការអភិវឌ្ឍន៍ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធចូលទៅដល់សហគមន៍ពួកគេក៏ដោយ។

តែនាពេលបច្ចុប្បន្ននេះយើងមើលឃើញថាប្រជាពលរដ្ឋកម្ពុជាយើងបានកំពុងតែរងគ្រោះជាថ្មីក្នុងសម័យទំនើបក្រោមរូបភាពនៃការអភិវឌ្ឍន៍ដែលមិនមានតម្លាភាពយុត្តិធម៌ព្រោះមានការរំលោភសិទ្ធិមនុស្សគ្រប់ទីកន្លែងបុគ្គលអ្នកមានអំណាចមួយចំនួនធ្វើការគៀបសង្កត់គំរាមគំហែង ប្រព្រឹត្តអំពើពុករលួយ គ្មានការអនុវត្តច្បាប់និងអភិបាលកិច្ចល្អក្នុងការទាញយកធនធានរបស់រដ្ឋ ធ្វើអោយមានគម្លាតរវាងអ្នកមាន និងអ្នកក្រសង្គមកម្ពុជាធ្លាក់ចូលទៅក្នុងភាពអសន្តិសុខដូចជាការប្រើប្រាស់គ្រឿងញៀននិងចោរកម្មមានការរើសអើងប្រជាពលរដ្ឋភាគច្រើនមិនមានភាពជាម្ចាស់លើដីធ្លីរបស់ខ្លួន មិនមានការអភិវឌ្ឍន៍នៅនិងមូលដ្ឋានជាក់ស្តែង ប្រជាពលរដ្ឋភាគច្រើន ជាពិសេសប្រជាពលរដ្ឋក្រីក្រ និងជនជាតិដើមភាគតិចដែលបានក្លាយជាជនរងគ្រោះបំផុត ហើយក្លាយជាកម្មករចំណាក់ស្រុក បាត់បង់មុខរបរ និងអត្តសញ្ញាណវប្បធម៌របស់ខ្លួន ដែលនិងអាចបាត់បង់ពូជសាសន៍ខ្លួនចេញពីផែនទីពិភពលោកនៅពេលដ៏ខ្លីខាងមុខនេះ។

ដោយសារតែបញ្ហាទាំងនេះ ទើប**គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា** ត្រូវបានបង្កើតឡើងក្រោមការសំនូមពរ និងឆន្ទៈរបស់ប្រជាពលរដ្ឋមូលដ្ឋានដើម្បីជួយដោះស្រាយនូវឫសគល់នៃបញ្ហាដែលពួកគេកំពុងប្រឈមជាក់ស្តែង។គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា បានចុះបញ្ជីជាផ្លូវការនៅក្រសួងមហាផ្ទៃនៅថ្ងៃទី៣០ ខែមករា ឆ្នាំ ២០១៧។ គណបក្សនេះត្រូវបានបង្កើតឡើង និងដឹកនាំដោយដោយក្រុមជនជាតិដើមភាគតិច
ឆ្លងកាត់ការពិគ្រោះយោបល់ជាលក្ខណៈសមូហភាពជាមួយសហគមន៍មូលដ្ឋានអស់រយៈពេលជាច្រើនឆ្នាំ
ក្នុងគោលបំណងជួយដោះស្រាយបញ្ហាដែលកើតមានឡើងនៅមូលដ្ឋានជាក់ស្តែងក្នុងប្រទេសកម្ពុជាដូចដែលមានចែងនៅក្នុងគោលនយោបាយទាំង៨ចំនុច ដោយមិនរើសអើងពូជសាសន៍ ជំនឿសាសនា និងនិន្នាការនយោបាយឡើយ។

ប្រជាពលរដ្ឋកម្ពុជា ជាទីគោរពស្រលាញ់! ថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៧ ខាងមុខនេះ ត្រូវនឹងថ្ងៃអាទិត្យ គឺថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤ ដែលជាការបោះឆ្នោតដ៏សំខាន់បំផុតក្នុងការកែប្រែដំណើរការអភិវឌ្ឍន៍ ឃុំ សង្កាត់នីមួយៗនិងជាថ្ងៃដែលយើងមានសិទ្ធិអំណាចពេញទីក្នុងការធ្វើជាម្ចាស់ដើម្បីសំរេចនូវជោគវាសនានិងការអភិវឌ្ឍន៍ដែលយើងចង់បាន។ អាស្រ័យហេតុនេះ សូមប្រជាពលរដ្ឋកម្ពុជា ទាំងអស់ដែលជឿជាក់លើគោលនយោបាយរបស់ គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា សូមអញ្ជើញទៅបោះឆ្នោតគាំទ្រ គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា ដែលមាន "**ពណ៌ខ្មៅខាង ជុំវិញរាងព្រះច័ន្ទពេញបូរមី មានមនុស្សជិះដំរីនៅកណ្តាល**" ជាសញ្ញាសម្គាល់ អោយបានគ្រប់គ្នាកុំបីខាន នៅតាមការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន។

គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា សូមប្តេជ្ញាចំពោះមុខប្រជាពលរដ្ឋកម្ពុជាថា និងធ្វើការកែប្រែការអភិវឌ្ឍន៍នៅមូលដ្ឋានអោយមានតម្លាភាព យុត្តិធម៌ សមធម៌ និងប្រកបដោយនិរន្តរភាព ព្រមទាំងយកប្រជាពលរដ្ឋជាធំ។

សូមជូនពរអោយប្រជាពលរដ្ឋកម្ពុជា បានជួបប្រទះសុខភាពល្អ រីកចំរើន និងសុភមង្គលជារៀងរហូត។

មណ្ឌលគិរី, ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០១៧

**ប្រធានគណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា**

**ឆ្លាខ ស៊ីន**

## 1 ចូលទៅក្នុងការិយាល័យបោះឆ្នោត

-បញ្ជាក់អត្តសញ្ញាណរបស់អ្នក-



## 2 គូសលើសន្លឹកឆ្នោត

-ត្រូវប្រាកដថា គឺសន្លឹកឆ្នោតអ្នកបានការ-



គូសនៅក្នុងប្រអប់តែមួយប៉ុណ្ណោះ

## 3 ការស៊កសន្លឹកឆ្នោត

-ស៊កសន្លឹកឆ្នោតចូលទៅក្នុងហិបឆ្នោត-



គ.ជ.ប

## 4 ជ្រលក់ ម្រាមដៃជាមួយនឹងទឹកខ្មៅលុបមិនជ្រះ

-អ្នកអាចបោះឆ្នោតបានតែម្តងប៉ុណ្ណោះ-



JICA

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការដ្ឋាន**
លេខ ១០០ គ.ជ.ប/អគ្គ./ប្រ.ក.ព

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៧

**កម្មវិធីផ្សព្វផ្សាយគោលនយោបាយ និងកម្មវិធីនយោបាយរបស់គណបក្ស**
**តាមស្ថានីយវិទ្យុ និងទូរទស្សន៍រដ្ឋ ក្នុងពេលឃោសនាបោះឆ្នោត**
**ចាប់ពីថ្ងៃទី២០ ខែឧសភា ដល់ថ្ងៃទី០២ ខែមិថុនា ឆ្នាំ២០១៧**

| **ពេល** | **ទូរទស្សន៍ជាតិកម្ពុជា** ( **ទទក** ) | **វិទ្យុ** AM 918 KHz | **វិទ្យុ** FM 96 MHz | **វិទ្យុទក្ខតំ** FM 105.70 MHz |
|---|---|---|---|---|
| **ព្រឹក** | | 5:30 នាទី - 7:00 នាទី | 7:30 នាទី - 9:00 នាទី | 5:30 នាទី - 7:00 នាទី |
| **រសៀល** | 13:00 នាទី - 14:30 នាទី | 15:10 នាទី - 16:40 នាទី (ផ្សាយឡើងវិញ) | | 15:10 នាទី - 16:40 នាទី (ផ្សាយឡើងវិញ) |
| **យប់** | 20:00 នាទី - 21:30 នាទី (ផ្សាយឡើងវិញ) | | 22:30 នាទី - 24:00 នាទី (ផ្សាយឡើងវិញ) | |

# គណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះ
# បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៤
## នៅថ្ងៃអាទិត្យ ទី០៤ ខែមិថុនា ឆ្នាំ២០១៧

គ.ជ.ប

| | |
|---|---|
| 1 | គណបក្សប្រជាជនកម្ពុជា<br>ប្រ.ជ |
| 2 | គណបក្សសង្គ្រោះជាតិ<br>គ.ស.ជ |
| 3 | គណបក្ស ហ៊្វុនស៊ិនប៉ិច<br>រ រ ជ ក ឯ អ ស ស |
| 4 | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ<br>គ.ស.ប |
| 5 | គណបក្ស ខ្មែររួបរួមជាតិ<br>ខ.រ.ជ |
| 6 | គណបក្សសំបុកឃ្មុំសង្គមប្រជាធិបតេយ្យ<br>គ.ស.ស.ប |
| 7 | គណបក្ស សញ្ជាតិកម្ពុជា<br>គ.ស.ក |
| 8 | គណបក្សប្រជាធិបតេយ្យមូលដ្ឋាន<br>គ ប ម |
| 9 | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ<br>គ.ស.រ.ប |
| 10 | គណបក្សយុវជនកម្ពុជា<br>គ.យ.ក |
| 11 | គណបក្សអំណាចខ្មែរ<br>គ.អ.ខ |
| 12 | គណបក្សជនជាតិដើមប្រជាធិបតេយ្យកម្ពុជា<br>គ.ជ.ប.ក |

**កំណត់សម្គាល់ : នេះមិនមែនជាសន្លឹកឆ្នោតទេ**